វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Cambodian Rubber Research Institute

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០១៨






# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ថ្ងៃសុក្រ៦រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក  ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (**វសកក**) មានកិត្តិយសក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពកាងារស្រាវជ្រាវប្រចាំឆ្នាំ២០១៨ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះបង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់ការិយាល័យមានដូចជា (១)ការិយាល័យបង្កាត់ពូជ ២)ការិយាល័យដាំដុះ និងការពារ (៣) ការិយាល័យសរីរវិទ្យា និងអាជីវកម្ម (៤) មន្ទីរពិសោធន៍ជាតិយថាប្រភេទ ព្រមទាំងការិយាល័យពាក់ព័ន្ធមួយចំនួនទៀតក្រោមឱវាទ **វសកក**។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារ កិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិត និងថ្នាក់ដឹកនាំ **វសកក** ទាំងអស់នៅក្នុងការពិសោធ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្ដាដៃគូអន្តរជាតិផ្សេងទៀតមានដូចជា: CIRAD, IRRDB, AFD, CATAS, UNIDO, HRPP ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចេរភាព។

ខ្ញុំសង្ឃឹមថា ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូនឹងទទួលបាននូវព័ត៌មានផ្សេងៗពីការពិសោធន៍ ស្រាវជ្រាវដំណាំកៅស៊ូតាមរយៈរបាយការណ៍នេះ ព្រមទាំងចូលរួមសហការ ផ្ដល់នូវមតិគាំទ្រ កែលម្អនិងតម្រង់ទិសការងារពិសោធស្រាវជ្រាវ ហើយនិងការរៀបចំនូវរបាយការណ៍សកម្មភាពនេះឲ្យមានលក្ខណៈកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ៦រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨

**នាយក**

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

**ម៉ក់ សុភាវាស្នា**

# មាតិកា

ទំព័រ


អារម្ភកថា ........ ii

១. សេចក្តីផ្តើម ........ 1

២. អង្គការលេខ និងស្ថានភាពបុគ្គលិក ........ 2

២.១. អង្គការលេខ ........ 2

២.២ ស្ថានភាពបុគ្គលិក ........ 3

៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក ........ 3

៣.១. សមិទ្ធផល ........ 3

៣.១.១. ផ្នែកក្សេត្រសាស្ត្រ ........ 3

៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ ........ 4

៣.១.៣. ការបណ្តុះបណ្តាល ........ 5

៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ 6

៣.២. លទ្ធផលតាមផ្នែក ........ 8

៣.២.១. ការិយាល័យបង្កាត់ពូជ ........ 8

៣.២.២. ការិយាល័យដាំដុះ និងការពារ ........ 12

៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម ........ 14

៣.២.៤. មន្ទីរពិសោធន៍ជាតិយថាប្រភេទ ........ 16

៣.៣ ការអនុវត្តថវិកាកម្មវិធី ........ 16

៣.៣.១. ចង្កោមសកម្មភាពទី១(១.៧.១.) ........ 17

៣.៣.២. ចង្កោមសកម្មភាពទី២(១.៧.២.) ........ 17

៣.៣.៣. ការទទួលធ្វើសាវនកម្មផ្ទៃក្នុង និងក្រៅការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ និងស្រាវជ្រាវ ........ 18

៤. ការបោះពុម្ព និងផ្សព្វផ្សាយ ........ 19

៥. ទិសដៅការងារឆ្នាំ២០១៩ និងសន្និដ្ឋាន ........ 20

៥.១. ទិសដៅការងារឆ្នាំ២០១៩ ........ 20

៥.២. សេចក្តីសន្និដ្ឋាន ........ 20

៦. ការប្រជុំ និងសិក្ខាសាលា ........ 21

៦.១. ការប្រជុំ និងសិក្ខាសាលាក្នុងប្រទេស ........ 21

៦.២. ការប្រជុំ និងសិក្ខាសាលានៅក្រៅប្រទេស ........ 26

៧. រូបភាពសកម្មភាពផ្សេងទៀត ........ 31

## ១. សេចក្តីផ្តើម

កៅស៊ូធម្មជាតិជាដំណាំសេដ្ឋកិច្ច និងយុទ្ធសាស្ត្រយ៉ាងសំខាន់ ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនលើសលប់ដល់អ្នកដាំ ផ្តល់ជាចំណូលដល់សេដ្ឋកិច្ចជាតិនិងសង្គម ព្រមទាំងបរិស្ថាន។ ជាការឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្ម នៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណត្តិទី៥ ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ក្រសួងកសិកម្មបានលើកឡើងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៤-២០១៨ ទិសដៅគោលនយោបាយរួមសំដៅ ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥% ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្មនិងពាណិជ្ជូបនីយកម្ម និងការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្មដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្រ ក្នុងបរិបទនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ ក្នុងនោះ **វសកក** ស្ថិតនៅក្នុងកម្មវិធីទី១ គឺ៖ **បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម។**

**វសកក** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំតម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ **វសកក** ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធីទី១ និងអនុកម្មវិធីទី១.៧ ស្តីអំពី៖ « **ការលើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាព គុណភាពផលិតផលកៅស៊ូកម្ពុជា** » ដែលក្នុងនោះមានចង្កោមសកម្មភាព០៣ គឺ៖ **១.៧.១.** *ការអភិរក្ស និងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ។* **១.៧.២.** *ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ។* **១.៧.៣.** *ការទទួលធ្វើសវនកម្មផ្ទៃក្នុង និងក្រៅការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិ ការចូលរួមវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។*

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗ របស់ **វសកក** ឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៤-២០១៨ ហើយនិងផែនការរយៈពេលវែងនិងខ្លីរបស់ **វសកក** ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធីដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែម បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ ហើយនិងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

# ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

## ២.១. អង្គការលេខ




***យោង៖*** *-អនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល*

*-អនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧*

***វសកក*** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារថា៖ ***វសកក*** *មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញ ផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម*។ នៅក្នុងអនុក្រឹត្យមានកាតព្វកិច្ចចំនួន៦ ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើង សំដៅលើការអនុវត្តឲ្យបានសម្រេចឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ ***វសកក*** តាមរយៈប្រកាសលេខ៥៧៦ ប្រក.កសក.បុ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ ***វសកក*** មានការិយាល័យ និងអង្គភាពចំណុះចំនួន៧ រួមមាន៖

១-ការិយាល័យ រដ្ឋបាល និងបុគ្គលិក

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យ បង្កាត់ពូជ

៤- ការិយាល័យ ដាំដុះ និងការពារ

៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម

៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ

៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

### ២.២ ស្ថានភាពបុគ្គលិក

មន្ត្រី ***វសកក*** ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤៥នាក់ ក្នុងនោះមានស្ត្រី០៩នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប៣០៤ នាក់។ មន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៥នាក់មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ០៧នាក់ |
| + បរិញ្ញាបត្រ | ៣២នាក់ |
| + បរិញ្ញាបត្ររង | ០៣នាក់ |
| + បឋមឯកទេស | ០២នាក់ |
| និងមន្ត្រីជាប់កិច្ចសន្យា | ២០នាក់ |

## ៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក

### ៣.១. សមិទ្ធផល

ការបំពេញភារកិច្ចក្នុងឆ្នាំ២០១៨ ក៏ដូចបណ្តាឆ្នាំមុនៗកន្លងមកដែរ ***វសកក*** បានខិតខំបន្តអនុវត្តការងារស្រាវជ្រាវ និងពិសោធន៍ឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត ***វសកក*** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

#### ៣.១.១. ផ្នែកក្សេត្រសាស្ត្រ

- ការអភិវឌ្ឍបច្ចេកទេសបំបៅ ដោយការបំបៅកូនកៅស៊ូតូច និងការផ្សាំកូនកៅស៊ូក្នុងបំពង់ Mini Budding trainer & Root trainer

- ការរៀបចំចម្ការពិសោធន៍ថ្មីចំនួន០២ អំពី (១)ការដាំដុះដំណាំចន្លោះរង (២)កៅស៊ូវៃឆ្លាត-ការបន្សាំ ទៅនឹងបម្រែបម្រួលអាកាសធាតុ លើផ្ទៃដីសរុបចំនួន១៩ហ.ត
- ការផ្សាំកូនកៅស៊ូបំបៅតូចនៅក្នុងបំពង់ Root Trainer ដោយក្លូន GT1 ចំនួន២២០ដើម, IRCA 230 ចំនួន៧២០ដើម និងRRIM600 ចំនួន២០០ដើម
- ការចុះយកទិន្នន័យទំហំដើម កម្ពស់ដើមកៅស៊ូ សំណាកស្លឹក និងសំណាកដី នៅតាមចម្ការកៅស៊ូចំនួន១៣០ ទីតាំង នៅក្នុងខេត្តចំនួន១៩ ដែលមានដាំកៅស៊ូរួមមាន៖

| | | | |
|---|---|---|---|
| + ខេត្តកំពង់ចាមចំនួន | (១១ទីតាំង) | + ខេត្តកំពង់ធំ | (១១ទីតាំង) |
| + ខេត្តសៀមរាប | (០៦ទីតាំង) | + ខេត្តព្រះវិហារ | (០៦ទីតាំង) |
| + ខេត្តឧត្តរមានជ័យ | (០៦ទីតាំង) | + ខេត្តបន្ទាយមានជ័យ | (០៥ទីតាំង) |
| + ខេត្តពោធិ៍សាត់ | (០៨ទីតាំង) | + ខេត្តបាត់ដំបង | (០៧ទីតាំង) |
| + ខេត្តប៉ៃលិន | (០៣ទីតាំង) | + ខេត្តកំពត | (០២ទីតាំង) |
| + ខេត្ត ព្រះសីហនុ | (០៥ទីតាំង) | + ខេត្តកោះកុង | (០៤ទីតាំង) |
| + ខេត្តព្រៃវែង | (០១ទីតាំង) | + ខេត្តស្វាយរៀង | (០៤ទីតាំង) |
| + ខេត្តត្បូងឃ្មុំ | (១២ទីតាំង) | + ខេត្តក្រចេះ | (១០ទីតាំង) |
| + ខេត្តស្ទឹងត្រែង | (០៩ទីតាំង) | + ខេត្តរតនគីរី | (១៣ទីតាំង) |
| + ខេត្តមណ្ឌលគីរី | (៧ទីតាំង) | | |

សំណាកស្លឹក និងសំណាកដីត្រូវបានយកនៅទីតាំងចម្ការ ដែលបានដាំក្នុងឆ្នាំ២០១៣ នៅដើមកៅស៊ូមិនមានការកាត់ចុង និងធ្វើលើក្លូនចំនួន០៣គឺៈ GT1, RRIM600 និងPB260។ គោលបំណងនៃការសិក្សានេះដើម្បី (១)ស្វែងយល់អំពីទំនាក់ទំនងរវាងលក្ខណៈរបស់ដីជាមួយនឹងការលូតលាស់របស់ដើមកៅស៊ូ (២)ធ្វើអនុសាសន៍អំពី ការដាក់ជីអំឡុងកៅស៊ូមិនទាន់ផ្តល់ផល ដោយផ្អែកលើលក្ខខណ្ឌជាក់ស្តែងនៅចម្ការកៅស៊ូ និង(៣)ការបង្កើតផែនទីសម្រាប់ធ្វើអនុសាសន៍ទៅតាមប្រភេទដីផ្សេងៗគ្នាទៅតាមតំបន់ដាំដុះកៅស៊ូនៅក្នុងប្រទេសកម្ពុជា។

- ការកែលម្អច្បារពូជចាស់ដែលអស់សក្តានុពលក្នុងការប្រើប្រាស់ និងរៀបចំដាំថ្មីឡើងវិញចំនួន២,៥ហ.ត រួមនិងការបំពាក់ប្រព័ន្ធស្រោចស្រព
- ការអភិរក្ស និងថែទាំក្លូនកៅស៊ូទាំង៧៤ និងការថែទាំតាមដានសេណូទីបជម្រើសទាំង២០
- ការរៀបចំរបាយការណ៍បច្ចេកទេសសម្រាប់ឆ្នាំ២០១៧-២០១៨
- ការបង្កើតថ្នាលបណ្តុះកូនកៅស៊ូចំនួន៣៥០០០កូន សម្រាប់ការដាំដុះពិសោធនៅឆ្នាំ២០១៨-២០១៩
- ការរៀបចំបើកមុខចៀរចម្ការពិសោធន៍ក្លូនកៅស៊ូទ្រង់ទ្រាយធំចំនួន០១ពិសោធន៍ នៅក្រុមហ៊ុនចម្ការកៅស៊ូ SOC-FIN KCD ស្ថិតនៅខេត្តមណ្ឌលគិរី
- ការវិភាគសរីរៈសាស្ត្រទឹកជ័រ (Latex Diagnosis) គ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយ៍បានចំនួន៧៣៦ សំណាក
- ការបន្តតាមដាន និងយកទិន្នន័យបណ្តាចម្ការពិសោធន៍ទាំង៦០ ស្ថិតនៅក្នុងស្ថានីយ៍ និងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម។

### ៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ

- ការធ្វើតេស្តយថាប្រភេទកៅស៊ូបានចំនួន៣៤៥សំណាក សម្រាប់វាយតម្លៃសមត្ថភាព និងគុណភាពនៃការកែច្នៃជ័រនៅតាមបណ្តារោងចក្រ

- ការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក (Laboratories Parallel Test) បានចំនួនពីរលើកគឺ៖ លើកទី៥៣ និង៥៤ ដើម្បីវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋាន យោងតាមប្រកាសលេខ៤០៤ ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨
- ការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានឲ្យក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេន គ្រុប ខូ. អិលធីឌី ដែលមានអាសយដ្ឋាននៅ ភូមិ០៦ ឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- ការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានឲ្យក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេន គ្រុប ខូ. អិលធីឌី ដែលមានអាសយដ្ឋាននៅ ភូមិខោល ឃុំទំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ
- ការផ្ដល់សុពលភាពបន្ត លើការទទួលស្គាល់និងការអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា របស់រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ក្រុមហ៊ុន ស៊្វីហ្សរីសសស៍ (ខេមបូឌា) លីមីធីត។

### ៣.១.៣. ការបណ្ដុះបណ្ដាល

#### ❖ ការបណ្ដុះបណ្ដាលផ្ទៃក្នុង

ក្នុងការពង្រឹងគុណភាព និងសមត្ថភាពធនធានមនុស្សក្នុងការងារស្រាវជ្រាវ នៅឆ្នាំ២០១៨នេះ **វសកក** បានបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗ ក្នុងនោះរួមមាន៖

- ➢ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលក្រៅប្រទេស:
  - មន្ត្រីចំនួន០២រូប ទៅចូលរួមសិក្ខាសាលាអន្តរជាតិ សន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ នៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ (IRRDB) នៅប្រទេសកូឌីវ័រចំនួន០១លើក
  - មន្ត្រីចំនួន០៤រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាអន្តរជាតិនៅប្រទេសថៃ
  - មន្ត្រីចំនួន០១រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាល នៅប្រទេសស្រីលង្កា
  - មន្ត្រីចំនួន០៧រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំនៅប្រទេសចិន
  - មន្ត្រីចំនួន០១រូប ទៅចូលរួមកិច្ចប្រជុំនៅប្រទេសម៉ាឡេស៊ី។
- ➢ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស:
  - មន្ត្រីចំនួន០២រូប ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីអំពី ការបញ្ជ្រាបដាក់ឲ្យសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ នៅខេត្តសៀមរាប
  - មន្ត្រីចំនួន០៣រូប ចូលរួមកិច្ចប្រជុំបូកសរុបចំណូលចំណាយថវិកាឆ្នាំ២០១៧ និងលើកទិសដៅអនុវត្ត សម្រាប់ឆ្នាំ២០១៨ នៅខេត្តកែប
  - មន្ត្រីចំនួន០២រូប ចូលរួមកិច្ចប្រជុំរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ នៅខេត្តកំពង់ចាម
  - មន្ត្រីចំនួន០៥រូប ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីអំពី ជំនាញបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

#### ❖ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ

ក្នុងការរួមចំណែកដល់ការអភិវឌ្ឍដំណាំកៅស៊ូ ទន្ទឹមគ្នានឹងការអភិវឌ្ឍផ្ទៃក្នុងធនធានមនុស្ស **វសកក** បានយកចិត្តទុកដាក់ដល់ការបណ្ដុះបណ្ដាល ផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងផ្សេងៗទៅដល់ប្រតិបត្តិករកៅស៊ូ សំដៅផ្ដល់នូវចំណេះដឹង ចំណេះធ្វើ ហើយនិងបង្កើននូវភាពជឿជាក់និងឱកាសជោគជ័យ នៅក្នុងការវិនិយោគលើផលិតកម្មដំណាំកៅស៊ូ។ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ត្រូវបានអនុវត្តលើគ្រប់មុខជំនាញទៅតាមវិធីសាស្ត្រផ្សេងៗ ដែលអាចធ្វើទៅបានមានដូចជា៖

- ការបើកវគ្គបណ្ដុះបណ្ដាល និងការបង្ហាញនៅនឹងកន្លែងលើមុខជំនាញផ្សេងៗ ពាក់ព័ន្ធនឹងដំណាំកៅស៊ូ

- ការទទួលកសិករធ្វើទស្សនកិច្ចសិក្សា
- ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធព័ត៌មានវិទ្យា និងការផ្លាស់ប្តូរព័ត៌មាន
- ការបោះពុម្ព និងចែកផ្សាយឯកសារ
- ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សា
- ការរៀបចំសិក្ខាសាលា
- ការទទួលនិស្សិតធ្វើសារណា និងដឹកនាំសារណាចំនួន។

## តារាងសរុបនៃការបណ្តុះបណ្តាលធនធានមនុស្ស:

### ការបណ្តុះបណ្តាល និងផ្ទេរបច្ចេកវិទ្យា

| លរ | ឆ្នាំ | មន្ត្រី | ជនបង្គោល | ផ្ទេរ ប.ច ដល់និស្សិត | ដឹកនាំសារណា | សិក្ខាសាលា | បណ្តុះបណ្តាលកសិករ | ភ្ញៀវទស្សនកិច្ច. | សរុប |
|---|---|---|---|---|---|---|---|---|---|
| 1 | 1997 | 0 | 0 | 0 | 4 | 57 | 20 | 2 | 83 |
| 2 | 1998 | 0 | 0 | 0 | 1 | 0 | 5 | 2 | 8 |
| 3 | 1999 | 0 | 0 | 0 | 3 | 0 | 5 | 35 | 43 |
| 4 | 2000 | 0 | 20 | 0 | 0 | 0 | 14 | 2 | 36 |
| 5 | 2001 | 20 | 50 | 0 | 0 | 200 | 20 | 1 | 291 |
| 6 | 2002 | 22 | 98 | 0 | 2 | 0 | 35 | 4 | 161 |
| 7 | 2003 | 14 | 90 | 0 | 2 | 72 | 104 | 2 | 284 |
| 8 | 2004 | 12 | 40 | 0 | 9 | 55 | 22 | 2 | 140 |
| 9 | 2005 | 15 | 27 | 0 | 4 | 0 | 25 | 3 | 74 |
| 10 | 2006 | 21 | 120 | 0 | 6 | 180 | 40 | 20 | 387 |
| 11 | 2007 | 25 | 315 | 0 | 0 | 320 | 70 | 220 | 950 |
| 12 | 2008 | 0 | 0 | 25 | 1 | 65 | 120 | 7 | 218 |
| 13 | 2009 | 12 | 150 | 42 | 2 | 70 | 150 | 20 | 446 |
| 14 | 2010 | 10 | 41 | 70 | 13 | 250 | 180 | 5 | 569 |
| 15 | 2011 | 12 | 57 | 27 | 9 | 92 | 170 | 2 | 369 |
| 16 | 2012 | 7 | 48 | 24 | 12 | 125 | 220 | 7 | 443 |
| 17 | 2013 | 13 | 200 | 110 | 17 | 53 | 390 | 3 | 786 |
| 18 | 2014 | 13 | 10 | 161 | 13 | 196 | 280 | 11 | 684 |
| 19 | 2015 | 7 | 15 | 72 | 22 | 70 | 295 | 5 | 486 |
| 20 | 2016 | 10 | 25 | 100 | 13 | 354 | 350 | 225 | 1077 |
| 21 | 2017 | 4 | 20 | 32 | 8 | 227 | 345 | 25 | 657 |
| 22 | 2018 | 27 | 5 | 10 | 10 | 30 | 35 | 20 | 137 |
| សរុប | | **222** | **1331** | **663** | **151** | **2386** | **2895** | **621** | **8329** |

## ៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា **វសកក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការអន្តរជាតិជាច្រើនរួមមាន៖

- ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ អន្តរជាតិ និងសិក្ខាសាលាអន្តរជាតិផ្សេងៗ ។

ក្នុងនោះ **កម្ពុជា** បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្តីអំពី « **និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព** » ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមានគណៈប្រតិភូពីបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុបចំនួន៣៣០ នាក់។ នៅឆ្នាំ២០១៧ ***វសកក*** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ ដោយមានភ្ញៀវពីបណ្តាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺ៖ **កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី** អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

### ❖ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ ***វសកក*** បានធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍ (CIRAD) នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នៅ ***វសកក***។ ផ្អែកលើអនុស្សរណៈនេះក្នុងឆ្នាំ២០១៨ ជំនាញការ CIRAD បានបំពេញបេសកកម្មចំនួន ១ដង មកកាន់កម្ពុជា ដើម្បីជួយពង្រឹងសមត្ថភាពមន្ត្រី***វសកក*** និងការស្រាវជ្រាវឲ្យកាន់តែមានប្រសិទ្ធភាពឡើងថែមទៀត។

### ❖ កិច្ចសហប្រតិបត្តិការជាមួយ CATAS

កិច្ចសហប្រតិបត្តិការរវាង ***វសកក*** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើង ដោយបានចុះអនុស្សរណៈនៃការយោគយល់នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុង កូឡុមបូ ប្រទេស ស្រីលង្កា។ ក្នុងទិសដៅបង្កើននូវទំនាក់ទំនង និងសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ នៅឆ្នាំ២០១៨ នេះភាគី CATAS បានបំពេញបេសកកម្មចំនួនបីលើកមកកម្ពុជា ដើម្បីសិក្សាគម្រោងពិសោធន៍ស្រាវជ្រាវរួមគ្នាជាមួយ ***វសកក*** ព្រមជាមួយគ្នានោះបានចុះអនុស្សរណៈបំពេញបន្ថែម ដើម្បីបន្តសុពលភាពនៃកិច្ចសហប្រតិបត្តិការស្រាវជ្រាវរួមគ្នានៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨។ នៅចុងក្នុងឆ្នាំ២០១៨ នេះក្រុមអ្នកជំនាញការCATAS ប្រទេសចិនបានផ្ទេរនូវបច្ចេកវិទ្យាកៅស៊ូដល់ ***វសកក*** ដោយបាន សហការណ៍ និងបណ្តុះបណ្តាលមន្ត្រី ***វសកក*** អំពី «ការបំប៉ៅកូនកៅស៊ូតូច និងការផ្សាំកូនកៅស៊ូក្នុងបំពង់»។ ផ្តើមចេញពីបច្ចេកទេសខាងលើនេះ ***វសកក*** បានអភិវឌ្ឍវិធីសាស្ត្រដោយឡែកមួយទៀតគឺ៖ «ការបំប៉ៅកូនកៅស៊ូតូច និងផ្សាំកូនកៅស៊ូក្នុងថង់» វិធីសាស្ត្រថ្មីនេះមានប្រសិទ្ធផលខ្ពស់ ដោយអត្រាកូនកៅស៊ូបំប៉ៅរស់ក្នុងថង់ដែលអាចប្រើប្រាស់បាននៅក្នុងការដាំដុះមានអត្រាខ្ពស់ជាងធៀបទៅនឹងថ្នាលកូនកៅស៊ូបំប៉ៅក្នុងថង់ធម្មតាប្រមាណ២០-២៥%។

### ❖ អង្គការស្បៀងអាហារ និងកសិកម្ម (FAO)

អង្គការ FAO មានបំណងធ្វើការសិក្សាអំពីស្ថានភាពកសិករកៅស៊ូគ្រួសារ ក្នុងការរៀបចំយុទ្ធសាស្ត្រជួយអភិវឌ្ឍកៅស៊ូគ្រួសារនៃបណ្តាប្រទេសក្នុងតំបន់។ ***វសកក*** បានព្យាយាមបញ្ចុះបញ្ចូលអង្គការនេះ ដើម្បីផ្សាភ្ជាប់ទំនាក់ទំនងភាពជាដៃគូសហការណ៍ក្នុងការសិក្សាស្ថានភាពអំពីកៅស៊ូគ្រួសារនៅកម្ពុជា។ ក្នុងការសិក្សានេះអង្គការ FAO បានជ្រើសរើសប្រទេសក្នុងតំបន់ចំនួន០៣ ក្នុងកិច្ចដំណើរការគម្រោង (Monitoring System of Family Farms ) ក្នុងនោះមានប្រទេស**កម្ពុជា ថៃ** និង**មីយ៉ាន់ម៉ា**។ នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៨ លោកបណ្ឌិត Pierre Marie Bosc, ជំនាញការ FAO, ប្រចាំទីក្រុង ROM, ប្រទេស Italy បានអញ្ជើញមកបំពេញបេសកកម្មជាលើកដំបូងនៅកម្ពុជា ដើម្បីស្វែងយល់ និងប្រមែប្រមូលព័ត៌មានបឋម អំពីស្ថានភាពនៃការអភិវឌ្ឍនៃដំណាំកៅស៊ូនៅកម្ពុជា។

ក្នុងឱកាសនៃការបំពេញបេសកកម្មនៅកម្ពុជា លោកបណ្ឌិត Pierre Marie Bosc បានចូលសម្តែងការគួរសមចំពោះ **ឯកឧត្តមរដ្ឋមន្រ្តី វេង សាខុន** និងបានជម្រាបជូន **ឯកឧត្តមរដ្ឋមន្រ្តី** អំពីគោលបំណងនៃគម្រោង ហើយក៏បានស្នើសុំ **ឯកឧត្តមរដ្ឋមន្រ្តី** ជួយគាំទ្រដល់គម្រោងការងារនេះ។ បន្ទាប់ពីបេសកកម្មរបស់លោកបណ្ឌិត Pierre Marie Bosc នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ អង្គការ FAO បានបញ្ជូនលោក Joe, GyunBae មន្រ្តីជំនាញផ្នែករៀបចំគម្រោងឲ្យមកបំពេញបេសកកម្មនៅកម្ពុជាជាថ្មីម្តងទៀត ដើម្បីប្រមូលទិន្នន័យចាំបាច់ពាក់ព័ន្ធនឹងដំណាំកៅស៊ូ និងជាពិសេសកៅស៊ូគ្រួសារនៅកម្ពុជា សម្រាប់ដំណើរការបន្តនីតិវិធីក្នុងការសិក្សាគម្រោង Monitoring System of Family Farms ។



**ឯកឧត្តម វេង សាខុន** រដ្ឋមន្រ្តី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុញ្ញាតឲ្យបណ្ឌិត Pierre-Marie Bosc មន្រ្តីជាន់ខ្ពស់នៃអង្គការ FAO និងលោក **ម៉ក់ សុភាវ៉ាស្នា** ព្រមទាំងសហការីជួបសម្តែងការគួរសម និងពិភាក្សាការងារ អំពីការរៀបចំគម្រោងសិក្សាថ្នាក់តំបន់ ពាក់ព័ន្ធនឹងប្រទេសចំនួនបីគឺ **ព្រះរាជាណាចក្រកម្ពុជា ថៃ** និង**មីយ៉ាន់ម៉ា** ដើម្បីជួយដល់ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ

## ៣.២. លទ្ធផលតាមផ្នែក

### ៣.២.១. ការិយាល័យបង្កាត់ពូជ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- ត្រួតពិនិត្យការថែទាំ ការពារនិងប្រមូលទិន្នន័យគ្រប់ឡូត៍ពិសោធន៍ក្លូនដែលមានស្រាប់ ទាំងនៅក្នុង និងក្រៅស្ថានីយ៍រួមមាននៅខេត្តត្បូងឃ្មុំ មណ្ឌលគីរី និងព្រះវិហារ (ចំនួន២៤ឡូត៍ពិសោធន៍)
- រៀបចំទីតាំង និងស្រង់ទិន្នន័យជម្ងឺ *Oidium* ឆ្នាំ២០១៨ សម្រាប់ឡូត៍ពិសោធន៍ក្លូន នៅវិទ្យាស្ថាននិងនៅចម្ការកៅស៊ូក្រៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ(១៣ ឡូត៍ពិសោធន៍)

- រៀបចំប្រតិទិនចៀរជ័រនិងការប្រើប្រាស់ថ្នាំរំញោចឆ្នាំ២០១៨ សម្រាប់ឡូត៍ពិសោធន៍នៅ ក្នុងស្ថានីយបាន ចំនួន ១០ឡូត៍ពិសោធន៍



ការរៀបចំបង្កើត ថៃទាំច្បារពូជថ្មីសម្រាប់ផ្គត់ផ្គង់មែកពូជដល់ការបំបៅ
នៅស្ថានីយ៍អនុវត្ត ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



មន្ត្រីការិយាល័យបង្កាត់ពូជ **វសកក** ពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន SOCFIN KCD CO., LTD
អំពីពិធីសារពិសោធន៍  និងការវាស់ទំហំដើមចម្ការពិសោធន៍ពូជទ្រង់ទ្រាយធំ ដើម្បីតាមដានការលូតលាស់
ហើយនិងរៀបចំដាក់ឲ្យបើកមុខចៀរចម្ការពិសោធន៍ ក្នុងក្រុមហ៊ុន SOCFIN KCD CO., LTD
នៅឃុំប៊ូស្រា ខេត្តមណ្ឌលគីរី

- ថែទាំច្បារពូជកៅស៊ូក្នុងស្ថានីយលើផ្ទៃដីប្រមាណ៦,៦ហ.ត ដើម្បីផ្គត់ផ្គង់មែកពូជកៅស៊ូបម្រើដល់ការពិសោធស្រាវជ្រាវ
- រៀបចំបង្កើតច្បារពូជកៅស៊ូថ្មីចំនួន២ហិកតា និងការបំពាក់ប្រព័ន្ធស្រោចស្រពបានចំនួន២,៥ហ.ត នៅប្លុក២១&១១ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយ AFD។
- វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូនទាំងនៅក្នុងនិងក្រៅស្ថានីយសរុបបានចំនួន១៩ ពិសោធន៍
- រៀបចំបើកមុខចៀរឡូត៍ពិសោធន៍ថ្មី(នៅខេត្តមណ្ឌលគីរី)បានចំនួន១ឡូត៍ពិសោធន៍ លើផ្ទៃដីប្រមាណ ៦,២៧ហ.ត ដោយប្រើចង្វាក់ចៀរជ័រពីរខុសគ្នា d3 និងd6។

## ៣.២.២. ការិយាល័យដាំដុះ និងការពារ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- ថែទាំកូនកៅស៊ូមិនទាន់ឲ្យផល និងថ្នាលបណ្ដុះកូនកៅស៊ូក្នុងស្ថានីយអនុវត្ត
- ការស្រាវជ្រាវប្រើប្រាស់ជីលើកៅស៊ូមិនទាន់ឱ្យផល និងកៅស៊ូឱ្យផល
- ការស្រាវជ្រាវពិពិធកម្មដំណាំចន្លោះរងកៅស៊ូ
- ការស្រាវជ្រាវលើការស្រោចស្រពកូនកៅស៊ូ
- បន្តការតាមដានចម្ការពិសោធន៍
- ការថែទាំ និងគ្រប់គ្រងកូនកៅស៊ូមិនទាន់ឱ្យផលត្រូវបានអនុវត្តជាប្រចាំក្រោយពីការដាំដុះ ដែលជាទូទៅមានរយៈពេលមធ្យមចំនួន៦ឆ្នាំ មុននឹងដាក់បញ្ចូលក្នុងដំណាក់កាលជាកៅស៊ូប្រមូលផល។ ផ្ទៃដីនៃការដាំដុះកៅស៊ូក្នុងឆ្នាំ២០១៨មានទំហំ១៨.៧៥ហ.ត។ ផ្ទៃដីមិនទាន់ប្រមូលផលនៅក្នុងដំណាក់កាលថែទាំក្នុងឆ្នាំ២០១៨ មានចំនួន៨៤ហ.ត ។
- ថ្នាលបណ្ដុះកូនកៅស៊ូក្នុងឆ្នាំ២០១៨ ត្រូវបានរៀបចំចំនួន០,៣៥ហ.ត ដើម្បីបង្កើតជាជើងទម្រសម្រាប់ផ្ដល់ឱ្យការបំបៅ និងយកទៅដាំដុះពិសោធ និងការពង្រីកច្បារពូជនៅឆ្នាំ២០១៩។

### ❖ ការពិសោធអំពីការប្រើប្រាស់ជីនៅលើដំណាំកៅស៊ូ

***វសកក*** បានរៀបចំការពិសោធន៍អំពី ការប្រើប្រាស់ជីលើដំណាំកៅស៊ូ ដើម្បីពិនិត្យ និងអង្កេតអំពីឥទ្ធិពលនៃ





សកម្មភាពដាក់គ្រាប់កៅស៊ូបណ្ដុះ ក្នុងការរៀបចំថ្នាលបណ្ដុះកូនកៅស៊ូក្នុងថង់

នៅស្ថានីយអនុវត្ត ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

ប្រភេទដី ហើយនិងបរិមាណសមាសធាតុ N.P.K ទៅលើការលូតលាស់ នៃកូនកៅស៊ូ ហើយនិងទិន្នផលជ័រដែលទទួលបានពីការដាក់ជីពិសោធ នៅលើកៅស៊ូដែលកំពុងផ្តល់ផលតើមានការខុសប្លែកគ្នាយ៉ាងណាធៀបទៅនឹងកៅស៊ូដែលមិនបានដាក់ជី ដើម្បីមានមូលដ្ឋានធ្វើការសម្រេចចិត្តថាតើត្រូវប្រើជីឬយ៉ាងណា សម្រាប់ចងក្រងជាទិន្នន័យក្នុងការវិភាគ និងផ្តល់ជាអនុសាសន៍ដល់កសិករ។

❖ ចម្ការពិសោធន៍អំពីការធ្វើពិពិធកម្មដំណាំចន្លោះរងកៅស៊ូ

***វសកក*** បានរៀបចម្ការពិសោធន៍ចំនួនពីរក្នុងឆ្នាំ២០១៨ (១)ឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់និងទិន្នផលកៅស៊ូ ក្នុងគោលបំណង វាយតម្លៃឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់ និងទិន្នផលកៅស៊ូ ហើយនិងប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំចន្លោះរងកៅស៊ូ (២)ឥទ្ធិពល និងផលប៉ះពាល់នៃដំណាំគ្របដី និងការប្រើប្រាស់ជីទៅលើការលូតលាស់និងទិន្នផលកៅស៊ូ ហើយនិងការបង្កើតជីវម៉ាស់គ្រប់គ្រងជីជាតិដី។




ជំនាញការ CATAS បណ្តុះបណ្តាលមន្ត្រី ***វសកក*** អំពីវិធីបំបៅកូនកៅស៊ូតូច (mini-budding) និងការរៀបចំថ្នាលកូនកៅស៊ូប្រភេទផ្សាំកូនក្នុងបំពង់ (Root trainer) ហើយនិងការអភិវឌ្ឍវិធីសាស្ត្រថ្មី អំពីវិធីបំបៅកូនកៅស៊ូតូច &ផ្សាំកូនកៅស៊ូកូនកៅស៊ូក្នុងថង់ (Mini-budding and Root training in polybag)
នៅស្ថានីយអនុវត្តស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ




សកម្មភាពមន្ត្រីស្រាវជ្រាវនៃ ***វសកក*** ចុះប្រមូលទិន្នន័យការលូតលាស់
របស់កូនកៅស៊ូ និងការយកសំណាកដីទៅធ្វើការវិភាគ

### ៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

❖ ផ្នែកស្រាវជ្រាវអាជីវកម្ម

- ស្រង់ទិន្នន័យទឹកជ័រគ្រប់ចំការពិសោធន៍ ដែលមានស្រាប់នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយ ០១ឡូត៍ពិសោធន៍នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក
- វាស់ទំហំដើមកៅស៊ូតាមដានការលូតលាស់បានចំនួន១៤ ចម្ការពិសោធន៍
- វិភាគបរិមាណជ័រស្ងួត DRC តាមមេត្រូឡាក់, តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍ ចំនួនបីដងក្នុងមួយខែ លើចម្ការពិសោធន៍ចំនួន១៣ ក្នុងស្ថានីយ និង០១ចម្ការពិសោធន៍នៅ ក្រុមហ៊ុនក្រែក
- បានលាបថ្នាំរំញោច Ethephon បានចំនួន១៤ចំការពិសោធន៍
- ត្រួតពិនិត្យការប្តូរប្រព័ន្ធមុខចៀរលើចម្ការពិសោធន៍ចំនួន៤ IRAE02, IRAE03, IRAE09, IRAE10
- តាមដានការលាបថ្នាំរំញោចអេតេហ្វូន (Ethephon) នៅក្នុងការពិសោធន៍។



ចម្ការពិសោធន៍អំពីការធ្វើពិពិធកម្មប្រភេទដំណាំផ្សេងៗ រួមមាន៖ ដំណាំស្វាយ, ស្វាយចន្ទី, ចេក, ម្នាស់ នៅតាមចន្លោះរងកៅស៊ូ នៅស្ថានីយអនុវត្ត ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

នៅក្នុងខែតុលាឆ្នាំ២០១៨ ចម្ការពិសោធន៍ KRAE 0៣ បានអនុវត្តការចៀរជ័របានចំនួន៩ពន្លាក។ ទិន្នផលជ័រស្ងួតក្នុងខែតុលា គិតជាក្រាម/ដើម/ពន្លាក នៃបច្ច័យនីមួយៗ ប្រែប្រួលពី៦៤,១-៧១,២ក្រ ។ ទិន្នន័យជ័រស្ងួតនៃបច្ច័យនីមួយៗ គិតជាគីឡូក្រាម/ហិកតា មានបម្រែបម្រួលពី ២២៤-២៤៤គ.ក្រ។




ក្រាហ្វិចតាងទិន្នន័យជ័រស្ងួតប្រចាំខែតុលា ឆ្នាំ២០១៨ នៅចម្ការពិសោធន៍ក្រុមហ៊ុនចម្ការកៅស៊ូក្រែក

❖ ផ្នែកមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យា

- លាយសូលុយស្យុងវត្ថុធាតុគីមីចំនួន១០មុខ សម្រាប់វិភាគរកស្តង់ដារនិងវិភាគសរីរសាស្ត្រទឹកជ័រ
- វិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រលើប៉ារ៉ាម៉ែត្របី Inorganic Phosphorus (Pi), Sucrose(Suc) ,និង Thiol (R-SH) បានចំនួន០៤ដងក្នុង១ខែ ដើម្បីផ្ទៀងផ្ទាត់វត្ថុធាតុគីមី
- ចុះយកសំណាកទឹកជ័របានចំនួន២៧ចម្ការពិសោធន៍ ស្មើនឹង៧៣៦សំណាកលើចម្ការពិសោធន៍នាន
- ក្នុងស្ថានីយស្រាវជ្រាវ សម្រាប់វិភាគសរីរសាស្ត្រទឹកជ័រក្នុងនោះរួមមាន៖
  + វិភាគសរីរសាស្ត្រទឹកជ័រ(LD) នៃពិសោធន៍ទាំង១៤ របស់ការិយាល័យសរីរៈ ស្មើនឹង១៥៦សំណាក
  + វិភាគសរីរសាស្ត្រទឹកជ័រ (LD) នៃចម្ការពិសោធន៍ របស់ការិយាល័យបង្កាត់ពូជចំនួន១០ ពិសោធន៍ ស្មើនឹង៤៨៤សំណាក
  + វិភាគស្តង់ដាសរីរសាស្ត្រទឹកជ័រ (LD) នៃចម្ការពិសោធន៍ ការិយាល័យដាំដុះនិងការពារ បានចំនួន ៤ចម្ការ ពិសោធន៍ ស្មើនឹង៩៦សំណាក។

❖ មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្ម បេសកកម្មត្រួតពិនិត្យចម្ការពិសោធន៍ ក្នុងក្រុមហ៊ុនចម្ការកៅស៊ូក្រែករៀង រាល់ខែដើម្បី៖

- ពិនិត្យបច្ចេកទេសប្រមូលផលទឹកជ័រ
- ពិនិត្យស្ថានភាពទូទៅចម្ការពិសោធន៍
- ត្រួតពិនិត្យការរៀបចំសម្ភារៈប្រមូលផលទឹកជ័រ
- ពិនិត្យតាមដានការសាប្រមូលផលទឹកជ័រ
- វាស់ទឹកជ័រតាមបច្ច័យនៃសារនីមួយៗ
- វិភាគរកបរិមាណជ័រស្ងួត (DRC) គ្រប់បច្ច័យនៃសារនីមួយៗ
- តាមដានការលាបថ្នាំរំញោចអេតេហ្វូន (Ethephon)។



មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្ម **វសកក** ចុះប្រមូលយកសំណាកទឹកជ័រ
នៅគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយ៍ ដើម្បីធ្វើការវិភាគសរីរសាស្ត្រគីមីទឹកជ័រ( LD )

### ៣.២.៤. មន្ទីរពិសោធន៍ជាតិយថាប្រភេទ

មន្ទីរពិសោធន៍យថាប្រភេទគឺជាផ្នែកដ៏សំខាន់មួយរបស់ **វសកក** និងជាមន្ទីរពិសោធន៍ជាតិដែលមានតួនាទីនៅក្នុងការពង្រឹងគុណភាពផលិតកម្មកៅស៊ូធម្មជាតិកម្ពុជា។ សកម្មភាពការងាររបស់មន្ទីរពិសោធន៍ក្នុងឆ្នាំ២០១៨ រួមមានៈ

- ក្រុមការងារនៃនាយកដ្ឋានវាយតម្លៃទទួលស្គាល់ (Department of Accreditation: DoA) ដឹកនាំដោយប្រធានក្រុមសវនករវាយតម្លៃគុណភាពមួយរូប (Lead assessor) និងសវនករវាយតម្លៃបច្ចេកទេសចំនួនពីររូប (Technical assessor) អមដោយជំនាញការបរទេសដែលមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងក្រុមប្រឹក្សាស្តង់ដារជាតិថៃ បានចុះសិក្សាវាយតម្លៃសាកល្បងនៅមន្ទីរពិសោធន៍ជាតិយថាប្រភេទនៃ **វសកក**
- ការរុះរើ វេចខ្ចប់ និងដឹកជញ្ជូនឧបករណ៍មន្ទីរពិសោធន៍ ដើម្បីផ្លាស់ប្តូរទីតាំងចាស់ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ០៩ ផ្លូវលេខ២៨៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទៅកាន់ទីតាំងថ្មី ស្ថិតនៅភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- ការចូលរួមត្រួតពិនិត្យស្ថានភាពមន្ទីរពិសោធន៍ថ្មីនៅឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- ការចូលរួមត្រួតពិនិត្យមើលការធ្វើតេស្តឧបករណ៍មន្ទីរពិសោធន៍ថ្មី
- ការរៀបចំរបាយការណ៍ស្ថានភាពឧបករណ៍ធ្វើតេស្តរបស់មន្ទីរពិសោធន៍
- ការចូលរួមក្នុងការតម្លើងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មី
- ការចូលរួមការធ្វើតេស្តឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មី
- ការចូលរួមវគ្គក្នុងបណ្តុះបណ្តាល នៃការប្រើប្រាស់ឧបករណ៍ និងសម្ភាររបស់មន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មី
- ការត្រួតពិនិត្យ និងដកចេញនូវសារធាតុគីមី ដែលផុតកាលបរិច្ឆេទនៃប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មី
- ការទទួលយកនិងប្រើប្រាស់មន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មីជាផ្លូវការ
- ការរៀបចំឡើងវិញនូវឧបករណ៍ និងសម្ភារចាស់ នៅក្នុងមន្ទីរពិសោធន៍ជាតិយថាប្រភេទថ្មី
- ការរៀបចំទៅតាមផ្នែករបស់ឧបករណ៍ និងសម្ភារៈ។





ការតម្លើងឧបករណ៍នៅមន្ទីរពិសោធន៍ថ្មី និងការធ្វើតេស្តឧបករណ៍ដែលបានតម្លើង
នៅមន្ទីរពិសោធន៍យថាប្រភេទ **វសកក** ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



ក្រុមការងារវាយតម្លៃ (Department of Accreditation: DoA) នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិភាក្សាការងារជាមួយមន្ត្រីមន្ទីរពិសោធន៍ជាតិយថាប្រភេទ និងអនុវត្ត ការវាយតម្លៃសាកល្បង មន្ទីរពិសោធន៍ជាតិយថាប្រភេទ **វសកក**



ការធ្វើតេស្តឧបករណ៍នៅមន្ទីរពិសោធន៍ថ្មី និងការបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍ អំពីការប្រើប្រាស់ឧបករណ៍ នៅមន្ទីរពិសោធន៍យថាប្រភេទ **វសកក**

- ការធ្វើតេស្តឧបករណ៍ និងសម្ភារដែលបានតម្លើងរួចនៅមន្ទីពិសោធន៏ជាតិយថាប្រភេទ
- ការចូលរួមធ្វើតេស្ត Round Robin ជាមួយប្រទេសម៉ាឡេស៊ី បានចំនួន២ដង

- ការចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ(CSR) ចំនួន២ និងមន្ទីរពិសោធន៍មូលដ្ឋានចំនួន១ នៅក្រុមហ៊ុនសុភិក្ខនិកា អ៊ិនវេសមេនគ្រុប ខូ., អិលធីឌី មានអាសយដ្ឋានៈ ភូមិ០៦ ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងភូមិខោល ឃុំទំរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដើម្បីចុះបញ្ជិកា
- ការចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ(CSR) និងមន្ទីរពិសោធន៍មូលដ្ឋាន របស់ក្រុមហ៊ុន ស៊ីហ្វរីសសស(ខេមបូឌា) លីមីធីត ដែលមានអាសយដ្ឋាន នៅភូមិរោងចក្រ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ដើម្បីបន្តសុពលភាពក្នុងការប្រើប្រាស់ស្លាកសញ្ញា(CSR)។

## ៣.៣ ការអនុវត្តថវិកាកម្មវិធី

***វសកក*** ជាគ្រឹះស្ថានសាធារណៈ និងជាអង្គភាពថវិកា ហើយស្ថិតក្នុងអនុកម្មវិធីទី១.៧ ស្តីអំពី៖ **លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាពគុណភាពផលិតផលកៅស៊ូកម្ពុជា** ដែលក្នុងនោះមានចង្កោមសកម្មភាព០៣គឺៈ ១.៧.១. ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ។ ១.៧.២. ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ។ ១.៧.៣. ការទទួលធ្វើសាវនកម្មផ្ទៃក្នុង និងក្រៅការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

### ៣.៣.១.ចង្កោមសកម្មភាពទី១ (១.៧.១.) « ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ»៖

ក្លូនកៅស៊ូគឺជាកត្តាចម្បងក្នុងការបង្កើនផលិតភាពនៃដំណាំកៅស៊ូ ក្លូនកៅស៊ូចាស់ៗត្រូវបានបាត់បង់ ដោយសារសង្គ្រាមស៊ីវិល និងកង្វះការអភិរក្សហើយនិងតម្លៃទាំត្រឹមត្រូវ។ ***វសកក*** បានខិតខំ កសាងនូវធនធានក្លូនកៅស៊ូឡើងវិញដោយការនាំចូលក្លូនកៅស៊ូពីបរទេស តាមរយៈនៃកិច្ចសហប្រតិបត្តិការជាដៃគូបច្ចេកទេសជាមួយបណ្តាអង្គការ មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្តាប្រទេសផ្សេងៗមួយចំនួន ដែលជាសមាជិកនៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ហើយនិងការខិតខំអភិវឌ្ឍក្លូនកៅស៊ូជាតិ ដើម្បីជំរុញការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជាប្រកបដោយនិរន្តរភាព។ ចម្ការពិសោធន៍ប្រៀបធៀបក្លូនចំនួន២៤ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៥ នៅតាមបណ្តាតំបន់មួយចំនួនក្នុងខេត្តត្បូងឃ្មុំ ព្រះវិហារ និងមណ្ឌលគីរី ផ្តើមចេញពីលទ្ធផលដែលទទួលបានពីការវិភាគទិន្នន័យចម្ការពិសោធន៍ទាំងនេះ អនុសាសន៍ក្លូនកៅស៊ូចំនួន៦លើក ត្រូវបានបង្កើតជាបន្តបន្ទាប់ ដែលជាមូលដ្ឋានសម្រាប់ចង្អុលបង្ហាញដល់ប្រតិបត្តិករ នៅក្នុងការដាំដុះនិងអភិវឌ្ឍន៍ដំណាំកៅស៊ូ។ បច្ចុប្បន្ន ***វសកក*** បានធ្វើការអភិរក្សក្លូនកៅស៊ូចំនួន៧៤ក្លូន រួមជាមួយនឹងការពង្រីកច្បារពូជប្រមាណ ៦ហ.ត ក្នុងការផ្គត់ផ្គង់មែកពូជសម្រាប់ការបំបៅ ដើម្បីដាំដុះពិសោធន៍និងចែករំលែកដល់ប្រតិបត្តិករ។

ការបង្កើតក្លូនកៅស៊ូត្រូវឆ្លងកាត់នូវដំណាក់កាលមួយដ៏វែងអន្លាយចាប់ពី២០-២៥ឆ្នាំ ហេតុដូច្នេះហើយ ***វសកក*** បានពុះពាររាល់ការលំបាក និងព្យាយាមរិះរកគ្រប់វិធីសាស្ត្រក្នុងការអភិវឌ្ឍក្លូនកៅស៊ូ ដែលក្នុងនោះមាន (១)ការនាំក្លូនចូលតាមរយៈកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គការ មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវជាដៃគូបច្ចេកទេស (២)ការបង្កើតឡើងនូវច្បារបង្កាត់ពូជ ដែលបានដាំនៅឆ្នាំ២០១៣ ដោយបណ្តាក្លូនជាមេបាដែលមានសក្តានុពលលូតលាស់ល្អ ទិន្នផលខ្ពស់ និងធនទ្រាំនឹងការរាតត្បាតពីជំងឺស្លឹក ជាពិសេសគឺភាពធនទ្រាំនឹងជំងឺ SALB (៣) ការអនុវត្តវិធីសាស្ត្រ ORTET ដើម្បីបង្កើតឡើងនូវ Clone ដែលវិធីនេះមានការបូកបញ្ចូលនូវការវិភាគសរីរសាស្ត្រទឹកជ័រ(DL) ក្នុងមន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា។ តាមរយៈវិធីទី៣នេះ ***វសកក***

បានអភិវឌ្ឍនូវធនធានសេណូទីបជម្រើសចំនួន២០ ដែលកំពុងដាំដុះថៃទាំ ហើយនិងត្រូវវាយតម្លៃនៅក្នុងអនាគតខ្លីខាងមុខ សម្រាប់ជាគោលដៅនៃការបង្កើតក្លូនកៅស៊ូថ្នាក់ជាតិ។

ក្លូនកៅស៊ូជាកត្តាសំខាន់នៅក្នុងការអភិវឌ្ឍ មធ្យោបាយនិងធនធានដាក់បញ្ចូលរួមមានបច្ចេកទេសដាំដុះតម្លៃទាំ និងការគ្រប់គ្រងជីជាតិដីជាជំហានបន្ទាប់ ដើម្បីញុាំងឲ្យកៅស៊ូមានការលូតលាស់ល្អ និងមានសុខភាពរឹងមាំម៉្យាងវិញទៀតការដាំដំណាំចន្លោះរួមផ្សំ វានឹងផ្តល់ទៅឲ្យកសិករនូវចំណូលបន្ថែម ជួយលើកស្ទួយដល់ជីវភាពរស់នៅរបស់កសិករកៅស៊ូគ្រួសារ។

នៅក្នុងចង្កោមសកម្មភាព**១.៧.១** នៅក្នុងអនុកម្មវិធី ១.៧ ដែលបានរំលេចក្នុងផែនការក្នុងឆ្នាំ២០១៨ ត្រូវបានកំណត់ដោយសូចនាករចុងក្រោយថាៈ «ក្លូនកៅស៊ូថ្មីសមស្របនឹងលក្ខខណ្ឌអាកាសធាតុកម្ពុជា ត្រូវបានវាយតម្លៃ និងដាក់បញ្ចូលក្នុងអនុសាសន៍ និងផ្សព្វផ្សាយឲ្យដាំដុះ រុក្ខសម្ភារៈកៅស៊ូត្រូវបានអភិវឌ្ឍ វិធីប្រើប្រាស់ជីមានប្រសិទ្ធភាព ធានាបាននូវការលូតលាស់នៃកូនកៅស៊ូ ព្រមជាមួយនិងកំណើនទិន្នផល ហើយនិងបច្ចេកទេសថែទាំកៅស៊ូត្រូវបានការណែនាំ»។ នៅក្នុងបរិបទនេះមានសូចនាករចំនួនបួនដែលត្រូវសម្រេចបានគឺៈ (១)ក្លូនកៅស៊ូថ្មីត្រូវបានបង្កើត ពាក់ព័ន្ធនឹងករណីយ៍នេះតាមការប៉ាន់ស្មានក្លូនកៅស៊ូថ្មីរបស់កម្ពុជាអាចនឹងសម្រេចបាននៅឆ្នាំ២០២៥ ប៉ុន្តែក្លូនដែលទទួលបាននោះអាចនឹងត្រូវដាក់ឆ្លងការពិសោធន៍បន្ត សម្រាប់តាមដានទិន្នន័យលើការប្រមូលផលទឹកជ័រ (២)ចំណុចដៅបន្តក្នុងចង្កោមសកម្មភាពនេះគឺផ្តោតទៅលើការអភិវឌ្ឍរុក្ខសម្ភារៈកៅស៊ូ ដែលករណីយ៍នេះយើងបាននិងកំពុងសហការណ៍ជាមួយនឹង CATAS ក្នុងការអភិវឌ្ឍរុក្ខសម្ភារៈប្រភេទ Mini budding និង Root Trainer ហើយកិច្ចការនេះស្ថិតក្នុងដំណាក់កាលពិសោធន៍នៅឡើយ (៣)សូចនាករទី៣ៈ សំដៅដល់វិធីប្រើប្រាស់ជី ក្នុងករណីនេះ ***វសកក*** កំពុងតាមដាននិងវាយតម្លៃចម្ការពិសោធន៍ជីចំនួន៦នៅក្នុងស្ថានីយ៍អនុវត្ត និងទិន្នន័យវិភាពដីនិងស្លឹកកៅស៊ូចំនួន១៣០ទីតាំង នៅក្នុង១៩ខេត្តផ្សេងទៀត ដែលស្ថិតនៅក្នុងដំណាក់កាលនៃការប្រមូលយកសំណាកនិងវិភាគនាពេលខាមុខ ***វសកក*** នឹងមានការរៀបចំជាសេចក្តីណែនាំអំពីការប្រើប្រាស់ជីសម្រាប់ដំណាំកៅស៊ូទាំងក្នុងដំណាក់កាលថែទាំ ទាំងក្នុងដំណាក់កាលនៃការប្រមូលផល (៤)ចំណុចដៅទី៤សំដៅដល់ណែនាំក្នុងការថែទាំកៅស៊ូ នៅក្នុងករណីនេះ ***វសកក*** បានធ្វើការបណ្តុះបណ្តាលដល់កសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករ កៅស៊ូជាញឹកញាប់រួចមកហើយ ព្រមទាំងមានការបោះពុម្ពជាក្រដាសផ្ទត់ចែកផ្សាយផងដែរ ព្រមជាមួយគ្នានោះក៏មានការរៀបចំជាចម្ការបង្ហាញទៀតផង។ នៅឆ្នាំ២០១៨ ***វសកក*** បានរៀបចំជាចម្ការបង្ហាញ០១ថ្មីទៀតក្រោមគម្រោងជំនួយហិរញ្ញប្បទានរបស់ AFD ស្តីអំពីកៅស៊ូវៃឆ្លាត-ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ដើម្បីជា មគ្គុទ្ទេសដល់ប្រតិបត្តិករកៅស៊ូទូទៅ នៅក្នុងការដាំដុះនិងថែទាំកៅស៊ូ។

### ៣.៣.២. ចង្កោមសកម្មភាពទី២ (១.៧.២.): « ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពកៅស៊ូកម្ពុជា ស្របទៅតាមនិយាមអន្តរជាតិ »៖

ការប្រមូលផលសម្រាប់ដំណាំកៅស៊ូខុសពីការប្រមូលផលចំពោះដំណាំប្រភេទផ្សេងទៀត ការប្រមូលផលដំណាំកៅស៊ូទាមទារនូវពលកម្មដែលមានជំនាញច្បាស់លាស់ ជាមួយនឹងការអនុវត្តខ្ជាប់ខ្ជួនស្របទៅតាមបទដ្ឋានបច្ចេកទេសហើយមាន ផែនការនិងពេលវេលាកំណត់ ព្រមជាមួយគ្នានោះក៏មានការប្រើប្រាស់ឲ្យបានត្រឹមត្រូវនូវធាតុចូលមួយចំនួនផងដែរ ដើម្បីថែរក្សាសុខដើម និងបង្កើនទិន្នផលប្រកបដោយស្ថិរភាព។ ការប្រមូលផលជ័រកៅស៊ូសមស្រប ដំណាំកៅស៊ូនឹងមានប្រក្រតីភាពក្នុងការលូតលាស់ និងសុខភាពល្អ អាចធានាបាននូវនិរន្តរភាពក្នុងការ ផ្តល់ផលបានយូរអង្វែងរហូតដល់២៥-៣០ឆ្នាំ។ ការប្រមូលផលកៅស៊ូមានការប្រែប្រួលទៅតាមដំណាក់កាល ពេលវេលា និងអាយុនៃដើមកៅស៊ូ និងមានការប្រែប្រួលទៅតាមលក្ខណៈសរីរៈសាស្ត្រនៃក្លូននីមួយៗ ដែលនឹងតម្រូវឲ្យមានការប្រើប្រាស់នូវធាតុចូលផ្សេងៗគ្នា ក្នុងការឆ្លើយតបទៅនឹងលក្ខណៈសរីរៈនៃក្លូនទាំងនោះ។

ក្រោយពីការប្រមូលផល ជ័រកៅស៊ូត្រូវឆ្លងកាត់នូវដំណាក់កាលកែច្នៃបឋមជាទម្រង់ដុំ(TSR) ជាមុនសិនទើបអាចធ្វើនិហរណកម្មបាន។ ផ្អែកលើលិខិតបទដ្ឋានគតិយុត្ត (អនុក្រិត្យលេខ៥៥អនក្រ.បក) ការធ្វើនិហរណកម្មជ័រកៅស៊ូកែច្នៃជាទម្រង់ដុំ(TSR) ត្រូវមានវិញ្ញាបនបត្របញ្ជាក់តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជាដើម្បីៈ (១) បង្កើនគុណភាពនៃការកែច្នៃកៅស៊ូកម្ពុជា (២)ផ្តល់ជំនឿទុកចិត្តដល់អតិថិជនជាតិ និងអន្តរជាតិក្នុងពាណិជ្ជកម្មកៅស៊ូ (៣)លើកស្ទួយគុណភាពកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ (៤)ការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (៥)សម្របសម្រួលការធ្វើអាជីវកម្ម ការកែច្នៃ ការនាំចេញ និងការធ្វើឯកជនភាវូបនីយកម្មយថាប្រភេទកៅស៊ូកម្ពុជា (៦)ការពារតម្លៃ និងបង្កើនភាពប្រកួតប្រជែងនៃកៅស៊ូកម្ពុជា (៧)បង្កើនចំណូលរដ្ឋលើពន្ធនាំចេញ ឬពន្ធផ្សេងទៀតពាក់ព័ន្ធនឹង បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា។

ចង្កោមសកម្មភាព១.៧.២ នៅក្នុងអនុកម្មវិធី ១.៧ ដែលត្រូវបានរំលេចក្នុងផែនការក្នុងឆ្នាំ២០១៨ និងបានកំណត់ដោយសូចនាករចុងក្រោយថាៈ «ការប្រមូលផលកៅស៊ូ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពចម្ការកោស៊ូ ហើយនិងបង្កើនបាននូវប្រសិទ្ធភាពពលកម្ម ហើយនិងវិញ្ញាបត្របញ្ជាក់គុណភាពកៅស៊ូត្រូវបានទទួលស្គាល់ជាអន្តរជាតិតាមរយៈIRA ក្នុងការទទួលសិទ្ធចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូសម្រាប់មន្ទីរពិសោធន៍មូលដ្ឋាន និងការរក្សាគុណភាព ហើយនិងការពារស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា(CSR)។ លទ្ធផលការងារសម្រេចបានឆ្លើយតបទៅនឹងគោលដៅដែលបានកំណត់រួមមាន៖ ការបង្កើតឡើងនូវចម្ការពិសោធន៍អំពីការប្រមូលផលទឹកជ័រកៅស៊ូនិងប្រព័ន្ធចៀរជ័រក្នុងន័យនេះ ដើម្បីសិក្សាអំពីសក្តានុពលទិន្នផលនៃបណ្តាបច្ច័យក្នុងចម្ការពិសោធន៍ ការវិភាគសរីរៈទឹកជ័រត្រូវបានអនុវត្តចំនួន០២ដង/ឆ្នាំ នៅគ្រប់ចម្ការពិសោធន៍ទាំងអស់នៅក្នុងស្ថានីយ៍ដើម្បីពិនិត្យមើលថាតើការប្រមូលផលកៅស៊ូឆ្លើយតបទៅនឹងសក្តានុពលនៃលក្ខណៈសរីរៈរបស់ក្លូនឬទេ។ ដោយឡែកនៅក្នុងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជា ការធ្វើតេស្តអន្តរមន្ទីរពិសោធន៍រវាង មន្ទីរពិសោធន៍យថាប្រភេទកម្ពុជា ជាមួយមន្ទីរពិសោធន៍នៃសមាគមកៅស៊ូអន្តរជាតិ ដែលមានទីតាំងនៅប្រទេសម៉ាឡេស៊ី ត្រូវបានអនុវត្តយ៉ាងទៀងទាត់ចំនួនពីរដង/ឆ្នាំ ដើម្បីពង្រឹងកិច្ចដំណើរការ សមត្ថភាព និងពិនិត្យនូវភាពជាក់លាក់នៅក្នុងការវិភាគគុណភាពជ័ររបស់មន្ទីរពិសោធន៍យថាប្រភេទកម្ពុជា។ ក្នុងការពង្រឹងគុណភាពជ័រកៅស៊ូ(CSR)នេះដែរ ទន្ទឹមនឹងការពង្រឹងសមត្ថភាពរបស់មន្ទីរពិសោធន៍ជាតិយថាប្រភេទកម្ពុជា ប្រព័ន្ធត្រួតពិនិត្យមួយត្រូវបានរៀបចំឡើងដោយការចង្អុលបង្ហាញតាមរយៈប្រកាសលេខ៤០៤ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនោះមន្ទីរពិសោធន៍យថាប្រភេទកម្ពុជា ត្រូវធ្វើតេស្តប្រៀបធៀប ជាមួយមន្ទីរពិសោធន៍កៅស៊ូក្នុងស្រុកទាំងអស់(Laboratories Parallel Test) ចំនួន៤លើក/ឆ្នាំ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន។ នៅឆ្នាំ២០១៨ នេះ គឺជាការធ្វើតេស្តប្រៀបធៀបលើកទី ៤៩, ៥០, ៥១ និងទី៥២។ ព្រមជាមួយគ្នានេះដែរ បណ្តារោងចក្រកែច្នៃកៅស៊ូដុំ(TSR) ដែលបានចុះបញ្ជីប្រើប្រាស់ស្លាកសញ្ញាកៅស៊ូ(CSR) ក៏ត្រូវឆ្លងកាត់ការត្រួតពិនិត្យចំនួន០២ដង/ឆ្នាំ ដោយមន្ត្រីជំនាញនៃមន្ទីរពិសោធន៍យថាប្រភេទផងដែរ។

### ៣.៣.៣. ការទទួលធ្វើសាវនកម្មផ្ទៃក្នុង និងក្រៅការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិ វិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ និងស្រាវជ្រាវ

ផ្នែកនេះស្ថិតនៅក្នុងចង្កោមសកម្មភាពទី១.៧.៣ នៃអនុកម្មវិធី ១.៧ នៅក្នុងផែនការក្នុងឆ្នាំ២០១៨ របស់ **វសកក**។ ផ្នែកនេះប្រតិបត្តិដោយការិយាល័យផែនការនិងគណនេយ្យ គឺជាផ្នែកផ្តល់សេវាផ្គត់ផ្គង់ដល់រាល់កិច្ចដំណើរការស្រាវជ្រាវរបស់ **វសកក** ទាំងមូល រួមទាំងការពិសោធន៍ស្រាវជ្រាវ ការផ្គត់ផ្គង់ទុព្ភសម្ភារៈបម្រើឲ្យកិច្ចការរដ្ឋបាល មន្ទីរពិសោធន៍ មធ្យោបាយដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធ ការបោះពុម្ពនិងផ្សព្វផ្សាយនិងផ្នែកផ្សេងទៀត។ ផ្នែកនេះនៅទទួលរ៉ាប់រងផងដែរទៅលើសេវាផ្គត់ផ្គង់ នៅក្នុងការទទួលធ្វើសាវនកម្មផ្ទៃក្នុង និងក្រៅពីការិយាល័យទទួលស្គាល់ (BoA-Bureau of Accreditation) ដែលមាននិវេសន៍ដ្ឋាននៅប្រទេសវៀតណាម ហើយនិងការបង់

វិភាគទានប្រចាំឆ្នាំផ្សេងទៀតតាមលក្ខន្តិកៈតម្រូវក្នុងនាម ***វសកក*** ជាសមាជិកពេញសិទ្ធ នៃបណ្តាអង្គការស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិទាំងនោះ។

## ៤. ការបោះពុម្ព និងផ្សព្វផ្សាយ

ឯកសារជាច្រើនប្រភេទត្រូវបានធ្វើការបោះពុម្ពផ្សាយ និងចែកចាយសំដៅផ្ទេរបច្ចេកវិទ្យានិងចែករំលែកព័ត៌មានដល់អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ និងប្រតិបត្តិករកៅស៊ូបានយល់ដឹងអំពីបច្ចេកទេសដាំដុះ ការគ្រប់គ្រងថែទាំកូនកៅស៊ូ ច្បារពូជ និងច្បារបង្កាត់ពូជ ការប្រើប្រាស់ជីក្នុងការថែបំប៉នកូនកៅស៊ូ និងនៅលើកៅស៊ូដែលកំពុងប្រមូលផល ការគ្រប់គ្រងជីជាតិដី បច្ចេកទេសនៃការប្រមូលផលទឹកជ័រ ការធ្វើពិពិធកម្មកៅស៊ូជាមួយប្រភេទដំណាំផ្សេងៗ រួមទាំងសកម្មភាពផ្សេងទៀតដែល ***វសកក*** បាននិងកំពុងអនុវត្ត។ នៅឆ្នាំ២០១៨ ឯកសារដែលវិទ្យាស្ថានបានបោះពុម្ពផ្សាយ និងចែកចាយដល់អង្គភាពពាក់ព័ន្ធ និងប្រតិបត្តិករកៅស៊ូរួមមាន៖

- របាយការបច្ចេកទេសប្រចាំឆ្នាំ២០១៦-២០១៧បានចំនួន១៥០ក្បាល
- ឯកសារស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០២០បានចំនួន២០០០ច្បា
- ឯកសារជា Posters បានចំនួន១២ផ្ទាំង។

### អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០២០

| ថ្នាក់១ | ថ្នាក់២ | ថ្នាក់៣ |
|---|---|---|
| IRCA 230<br>RRIM 600<br>PB 280<br>RRIC 121<br>IRCA 130 | GT 1<br>IRCA 109<br>RRIM 712<br>PB 235<br>PB 217<br>RRIC 101<br>RRIC 100<br>KV 4 | BPM 24<br>IRCA 111<br>IRCA 41<br>PR 303<br>PR 254<br>PB 310<br>PB 314<br>PB 324<br>PB 330<br>PR 261 |

## ៥.ទិសដៅការងារឆ្នាំ២០១៩ និងសន្និដ្ឋាន

### ៥.១. ទិសដៅការងារឆ្នាំ២០១៩

- រៀបចំបើកវគ្គបណ្តុះបណ្តាលស្តីអំពីបច្ចេកទេសកៅស៊ូ ដល់កសិករ
- ធ្វើតេស្តភាគសំណាកយថាប្រភេទកៅស៊ូពីបណ្តាក្រុមហ៊ុនចំការកៅស៊ូ
- ចុះត្រួតពិនិត្យឡូត៍ពិសោធន៍កូនកៅស៊ូនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ
- រៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៧-២០១៨ និងវិភាគសរីរៈទឹកជ័រគ្រប់ចំការពិសោធន៍
- តាមដានទិន្នផលកៅស៊ូចម្ការពិសោធជីលើក្លូន PB260, PB217, GT1 និង RRIM712
- ចុះបេសកកម្មទៅតាមបណ្តាមន្ទីរពិសោធន៍ និងរោងចក្រកែច្នៃកៅស៊ូក្រុមហ៊ុនចំការកៅស៊ូ
- ចូលរួមកិច្ចប្រជុំនិងសិក្ខាសាលាអន្តរជាតិនៅបរទេស
- ធ្វើការផ្លាស់ប្តូរក្លូនកៅស៊ូជាមួយបណ្តាប្រទេសដែលជាសមាជិក IRRDB
- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA
- រៀបចំធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក
- រៀបចំការដាំដុះចម្ការពិសោធន៍
- ចុះត្រួតពិនិត្យនិងវាយតម្លៃច្បារពូជកៅស៊ូរបស់ក្រុមហ៊ុនចម្ការកៅស៊ូនិងកៅស៊ូគ្រួសារ
- សហប្រតិបត្តិការជាមួយ CIRAD, CATAS, FAO និង IRRDB។

### ៥.២. សេចក្តីសន្និដ្ឋាន

សកម្មភាពនិងលទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិតទាំងអស់ជាមួយថ្នាក់ដឹកនាំ **វសកក** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវក្នុងបេសកកម្មរបស់ខ្លួននិងផែនការដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះក៏មានយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័នជំនាញជាអណាព្យាបាលរួមមាន៖ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** និង**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក្នុងការជំរុញការអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា ស្របតាមគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានមួយចំណែកដោយមានការចូលរួមពីបណ្តាដៃគូជាតិរួមមានប្រតិបត្តិករកៅស៊ូទាំងអស់ដែលបានផ្តល់ការទុកចិត្ត ចូលរួម និងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួម សហការពីបណ្តាដៃគូអន្តរជាតិពាក់ព័ន្ធដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS,...។

# ៦. ការប្រជុំ និងសិក្ខាសាលា

## ៦.១. ការប្រជុំ និងសិក្ខាសាលាក្នុងប្រទេស




ថ្ងៃច័ន្ទ ១០ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ លោក**ម៉ក់ សុភាវាស្នា** នាយក **វសកក** ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ាន់ សុគ្រី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





**ឯកឧត្តម ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល **វសកក** លើកទី២ អាណត្តិទី៥ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃពុធ ៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ នៅស្ថានីយពិសោធន៍កៅស៊ូរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លើកទី៣ អាណត្តិទី៥ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីអនុម័តលើសំណើសុំតែងតាំងមន្ត្រីរាជការវិទ្យាស្ថាន និងពិនិត្យវឌ្ឍនភាពការអនុវត្តការងារក្នុងឆមាសទី១ ឆ្នាំ២០១៨ និងកញ្ចប់ថវិកាឆ្នាំ២០១៩។ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ ឯកឧត្តមប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានអញ្ជើញធ្វើទស្សនកិច្ច បច្ចេកទេសបំបៅកូនកៅស៊ូតូច (Mini budding) និងថ្នាលបណ្ដុះកូនកៅស៊ូក្នុងបំពង់ ហើយនិងចំការពិសោធន៍កៅស៊ូរបស់វិទ្យាស្ថានមួយចំនួនទៀត ក្នុងគោលបំណងស្វែងយល់អំពីការងារពិសោធន៍ និងស្រាវជ្រាវដំណាំកៅស៊ូរបស់ **វសកក** ដើម្បីផ្ដល់ជាអនុសាសន៍ដល់វិទ្យាស្ថានអំពីចំនុចខ្វះចន្លោះដែលត្រូវបំពេញ និងការរៀបចំផែនការ ហើយនិងទិសដៅសម្រាប់អនុវត្តនាពេលអនាគត ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។



**ឯកឧត្តម ប៉ុល សុផា** អញ្ជើញជាអធិបតីដឹកនាំអង្គប្រជុំក្រុមប្រឹក្សាភិបាល **វសកក** និងដឹកនាំសមាជិកក្រុមប្រឹក្សាភិបាលធ្វើការត្រួតពិនិត្យវឌ្ឍនភាពការងាររបស់ **វសកក** នៅស្ថានីយអនុវត្ត ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



លោក **ម៉ក់ សុនាទាស្លា** នាយក **វសកក** ដឹកនាំការប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំខែរបស់ **វសកក**
និងការពិភាក្សាដោះស្រាយបញ្ហាផ្សេងៗ ហើយនិងការលើកទិសដៅសម្រាប់អនុវត្តក្នុងខែបន្តបន្ទាប់



ជំនាញការ CIRAD និង ជំនាញការក្រុមហ៊ុន GLG រួមសហការណ៍ជាមួយមន្ត្រី **វសកក**
ចុះសិក្សាលទ្ធភាពដែលអាចធ្វើបាននៃគម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារ
នៅខេត្តកំពង់ចាមថ្ងៃទី ១៦-១៨ ខែមករា ឆ្នាំ២០១៨



**ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ  អញ្ជើញធ្វើទស្សនកិច្ច
ការបំបៅកូនកៅស៊ូតូច នៅស្ថានីយ៍អនុវត្ត ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨





ជំនាញការ CIRAD  ចុះពិនិត្យស្ថានភាពចម្ការពិសោធន៍ និងពិភាក្សាការងារស្រាវជ្រាវជាមួយ
មន្ត្រីស្រាវជ្រាវ នៃ *វសកក* នៅស្ថានីយ៍អនុវត្តន៍ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨





ទស្សនកិច្ចរបស់គណៈប្រតិភូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS)
នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ពីថ្ងៃទី០៨-០៩ ខែឧសភា ឆ្នាំ២០១៨



កិច្ចប្រជុំពិភាក្សារវាងគណៈប្រតិភូ នៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) និងថ្នាក់ដឹកនាំ នៃ **វសកក** ដើម្បីពិនិត្យពិចារណាអំពីលទ្ធភាព ដែលអាចពិសោធន៍រួមគ្នារវាង CATAS និង **វសកក** នៅស្ថានីយ៍អនុវត្ត ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៨



មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្មពិភាក្សាការងារនិងផ្តល់ការណែនាំអំពីការគ្រប់គ្រងទឹកជ័រ ចម្ការពិសោធន៍ដល់ប្រធានក្រុមឡូត៍ពិសោធន៍ នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក

## ៦.២. ការប្រជុំ និងសិក្ខាសាលានៅក្រៅប្រទេស

នៅថ្ងៃទី១១-១៥ ខែធ្នូ ឆ្នាំ២០១៨ នាយក និងមន្ត្រី ***វសកក*** បានមកចូលរួមសិក្ខាសាលាថ្នាក់អ្នកវិទ្យាសាស្ត្រខាងដំណាំកៅស៊ូ Hevea Research Platform in Partnership (HRPP) នៅប្រទេសថៃក្នុងឱកាសនេះដែរ ***វសកក*** បានធ្វើបទបង្ហាញលើប្រធានបទមួយ ស្តីអំពីការផលិត និងកែច្នៃកៅស៊ូប្រភេទ TSR CV60 និង RSS CV60។ សារៈសំខាន់នៃសិក្ខាសាលានេះគឺពិភាក្សាគ្នាក្នុងកំរិតអ្នកវិទ្យាសាស្ត្រកៅស៊ូ ដើម្បីដោះស្រាយបញ្ហាប្រឈមនាលើវិស័យកៅស៊ូទៅអនាគត។



ទិដ្ឋភាពនៃការប្រជុំ HRPP នៅប្រទេសថៃ



លោក **ម៉ក់ សុភាវាស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានិងមន្ត្រីជំនាញចូលរួមក្នុងសិក្ខាសាលាស្តីអំពីវិទ្យាសាស្ត្រដំណាំកៅស៊ូ នៅប្រទេសថៃ ថ្ងៃទី១១-១៥ ខែធ្នូ ឆ្នាំ២០១៨




លោក **ម៉ក់ សុភាទាស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចូលរួមក្នុងសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ(IRRDB)នៅប្រទេសកូដឌីវ័រ




លោក **ម៉ក់ សុភាទាស្នា** នាយក *វសកក* ធ្វើបទបង្ហាញអំពីការពិសោធស្រាវជ្រាវរបស់ *វសកក* និងការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជា ជូនមន្ត្រី CATAS ក្នុងឱកាសទស្សនកិច្ចនៅប្រទេសចិន



លោក **ម៉ក់ សុភាទាស្នា** នាយក *វសកក* និងសហការី ទស្សនកិច្ចថ្នាលបណ្ដុះកូនកៅស៊ូក្នុងបំពង់ (Root Trainer) និងបច្ចេកទេសបំបៅកូនកៅស៊ូតូច(Mini Budding) នៅ CATAS ប្រទេសចិន



កិច្ចប្រជុំពិភាក្សាការងារបច្ចេកទេសរវាងមន្ត្រី CATAS និងមន្ត្រីនៃ **វសកក**





សកម្មភាពរៀបចំសំណាកដី សំណាកស្លឹក និងការរៀបចំសូលុយស្យុងសម្រាប់ធ្វើការវិភាគ
នៅក្នុងមន្ទីពិសោធន៍ CATAS



មន្ត្រី **វសកក** ទស្សនកិច្ចការធ្វើពិពិធកម្មដំណាំ
ចន្លោះរងដំណាំកៅស៊ូនៅ CATAS



មន្ត្រីCATAS បង្ហាញអំពីសកម្មភាពនិង ការ
អភិវឌ្ឍរបស់ CATAS ដល់មន្ត្រី **វសកក**



នាយក និងមន្ត្រីជំនាញ ***វសកក*** ទស្សនកិច្ចមន្ទីរពិសោធន៍វិភាគដី និងវិភាគស្លឹក នៅ CATAS



កិច្ចប្រជុំពិភាក្សារវាងថ្នាក់ដឹកនាំ ***វសកក*** និង ថ្នាក់ដឹកនាំ នៃនាយកដ្ឋានការពារដំណាំ CATAS



មន្ត្រី ***វសកក*** ទស្សនកិច្ចនៅមន្ទីរពិសោធន៍ និងវិភាគសត្វល្អិតនៅ CATAS

# វគ្គបណ្តុះបណ្តាល់អំពីការអនុវត្តន៍ស្ថិតិរបស់ (IRRDB) និង សិក្ខាសាលាស្តីពីផលប៉ះពាល់ នៃសង្គមសេដ្ឋកិច្ចដោយមូលហេតុកៅស៊ូធ្លាក់ថ្លៃ  នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូស្រីលង្កា ថ្ងៃទី០១ ដល់ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨






មន្ត្រី ***វសកក*** ធ្វើបទបង្ហាញអំពីផលប៉ះពាល់នៃកៅស៊ូធ្លាក់ថ្លៃ ក្នុងអង្គសិក្ខាសាលានៅប្រទេសស្រីលង្កា

គណៈប្រតិភូចូលរួមអង្គសិក្ខាសាលានៅ ប្រទេសស្រីលង្កា





ទស្សនកិច្ចរោងចក្រផលិតកៅស៊ូសន្លឹក

បច្ចេកទេសនៃការចៀរជ័រនៅស្រីលង្កា





រូបថតក្រុមសិក្ខាកាមនៃអង្គសិក្ខាសាលា IRRDB នៅប្រទេសលង្កា

## ៧. រូបភាពសកម្មភាពផ្សេងទៀត



ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញ
ត្រួតពិនិត្យមន្ទីរពិសោធន៍ រោងចក្រផលិតកៅស៊ូសន្លឹក នៅស្ថានីយ៍អនុវត្ត ***វសកក*** និងជួបសំណេះ
សំណាលជាមួយមន្ត្រី ***វសកក*** នៅស្ថានីយអនុវត្ត ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨



ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញ
ត្រួតពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវកៅស៊ូ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសោភ័ណភាព
នៅក្នុងបរិវេណស្ថានីយ៍អនុវត្ត ***វសកក*** ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨



សិក្ខាកាមនៃវគ្គបណ្តុះបណ្តាល ស្តីពីផលិតកម្មកៅស៊ូវ៉ែឆ្លាតខាងអាកាសធាតុ តាមរយៈការអនុវត្ត កសិកម្មល្អ ធ្វើទស្សនកិច្ចសិក្សានៅស្ថានីយអនុវត្តនៃ **វសកក** ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



និស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ធ្វើទស្សនកិច្ចសិក្សា ចម្ការផលិតកម្មកៅស៊ូវ៉ែឆ្លាតខាងអាកាសធាតុ តាមរយៈការអនុវត្តកសិកម្មល្អ នៅស្ថានីយអនុវត្តនៃ **វសកក** ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



គណៈប្រតិភូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(CATAS) មកទស្សនកិច្ចចម្ការពិសោធន៍
នៅស្ថានីយ៍អនុវត្ត នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



មន្ត្រីស្រាវជ្រាវ នៃ **វសកក** បានចូលរួមជាមួយអ្នកស្រាវជ្រាវនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន
(CATAS) ដើម្បីពិនិត្យតាមដានអំពីជំងឺ និងសត្វល្អិតដែលកើតមានលើដំណាំកៅស៊ូ
នៅខេត្តក្រចេះ ស្ទឹងត្រែង សៀមរាប និងខេត្តកំពង់ចាម



គណៈប្រតិភូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន CATAS ទស្សនកិច្ចចម្ការពិសោធន៍
នៅស្ថានីយ៍អនុវត្ត នៃ **វសកក** ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៨



មន្ត្រីការិយាល័យបង្កាត់ពូជ **វសកក** វាស់ទំហំដើមចម្ការពិសោធន៍ពូជទ្រង់ទ្រាយដើម្បីតាមដានការលូតលាស់
នៃដើមកៅស៊ូតាមបណ្តាក្លូន នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨



ចម្ការពិសោធន៍អំពីការស្រោចស្រពកូនកៅស៊ូ ដើម្បីសិក្សាអំពីតម្រូវការទឹកចំពោះកូនកៅស៊ូ និងភាពខុសគ្នា
នៃការលូតលាស់របស់កូនកៅស៊ូ  រវាងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ធៀបទៅនឹងរបបទឹកភ្លៀងប្រចាំឆ្នាំ



ដំណាំគ្របដីប្រភេទ (*Pueraria phaseoloides*)
ដាំចន្លោះរងកៅស៊ូ នៃការពិសោធកៅស៊ូវ៉ៃឆ្លាត
ដាំនៅខែកក្កដា ឆ្នាំ២០១៨



ដំណាំគ្របដីប្រភេទ (*Stylosanthes guianensis*)
ដាំចន្លោះរងកៅស៊ូ នៃការពិសោធកៅស៊ូវ៉ៃឆ្លាត
ដាំនៅខែកក្កដា ឆ្នាំ២០១៨



មន្ត្រីមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យា នៃ ***វសកក*** វិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ(LD)
នៅមន្ទីពិសោធន៍ ជីវគីមី និងសរីរវិទ្យា ក្នុងស្ថានីយ៍អនុវត្ត ***វសកក*** នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



មន្ត្រីមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យានៃ ***វសកក*** វិភាគបរិមាណជ័រស្ងួត DRC នៃទឹកជ័រ
ដើម្បីធ្វើការប្រៀបធៀបគ្នា រវាង DRC តាមវិធីសាស្ត្រមេត្រូឡាក់ និងតាមការដុតសម្ងួត



សកម្មភាពមន្ត្រីមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យានៃ ***វសកក*** វិភាគសរីរសាស្ត្រទឹកជ័រ (LD)
លើប៉ារ៉ាម៉ែត្រ  Inorganic Phosphorus (Pi), Sucrose(Suc) ,និង Thiol (R-SH)

# កិច្ចដំណើរការសាកល្បងមន្ទីរពិសោធន៍យថាប្រភេទថ្មី
# នៅក្នុងការធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១១៩ របស់ IRA



ការវិភាគវីស្កូម៉ែត្រមូនី



ការវិភាគពណ៌



សកម្មភាពលាយល្បាយធាតុគីមី



ការវិភាគ Po និង PRI



ការវិភាគអាសូត



សកម្មភាពកិនសំណាកជ័រឲ្យស្មើសាច់

## មន្ត្រី ***វសកក*** ចុះពិនិត្យរោងចក្រ និងមន្ទីរពិសោធន៍ ក្នុងការអនុវត្តនិតិវិធីនៃ ការចុះបញ្ជិការោងច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេនគ្រុប ខូ. អិលធីឌី ដើម្បីទទួលសិទ្ធ ប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR)




មន្ត្រីមន្ទីរពិសោធន៍យថាប្រភេទកៅស៊ូកម្ពុជានៃ ***វសកក*** ចុះប្រមូលព័ត៌មានពីការិយាល័យរដ្ឋបាល
និងប្រធានមន្ទីរសោធន៍ក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេនគ្រុប ខូ. អិលធីឌី ដើម្បីដំណើរការនិតិវិធីនៃការចុះបញ្ជិកា




មន្ត្រីមន្ទីរពិសោធន៍យថាប្រភេទ ***វសកក*** ចុះយកសំណាកជ័រកៅស៊ូ
នៅក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេនគ្រុប ខូ. អិលធីឌី ដើម្បីធ្វើការវិភាគប្រៀបធៀប




មន្ត្រីមន្ទីរពិសោធន៍យថាប្រភេទ ***វសកក*** ចុះពិនិត្យការគ្រប់គ្រងខ្សែប្រវាក់ផលិតកម្មរោងចក្រ
នៅក្រុមហ៊ុនសុភ្គិនីកា អ៊ិនវេសមេនគ្រុប ខូ. អិលធីឌី

## មន្ត្រីមន្ទីរពិសោធន៍ជាតិយថាប្រភេទនៃ ***វសកក*** ចុះត្រួតពិនិត្យការកែច្នៃជ័រកៅស៊ូ នៅតាមបណ្តារោងចក្រកែច្នៃកៅស៊ូ CSR



ពិនិត្យការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្មរោងចក្រ



ការពិនិត្យខ្សែច្រវាក់ផលិតកម្មក្នុងរោងចក្រ



ពិនិត្យការវេចខ្ចប់សំណាកនៅមន្ទីរពិសោធន៍



សកម្មភាពពិនិត្យខ្សែច្រវាក់ផលិតកម្មក្នុងរោងចក្រ



ការពិនិត្យលើការថ្លឹងសំណាកក្នុងមន្ទីរពិសោធន៍



ការពិនិត្យទិន្នន័យធ្វើ DRC របស់មន្ទីរពិសោធន៍